# ការវិវត្តន៍នៃគណៈបក្សប្រជាជនកម្ពុជា

ដំណើរនយោបាយវៀតទីនិយមនិងប្រល័យពូជសាសន៍របស់យួន  មានកលល្បិចនិងយុទ្ធសាស្ត្រជាច្រើនបត់បែនតាមតំណាក់កាលនិមួយៗ។ **កម្មវត្ថុរបស់យួនដែលបង្កើតបក្សកុំម្មុយនីស្តឥណ្ឌូចិន** គឺដើម្បីរៀបចំយុទ្ធសាស្ត្រ**លេបទឹកដី ខ្មែរ និងលាវដោយយកលិទ្ធិកុំម្មុយនីស្ត**ជាគោលក្រោមរូបភាពជាចលនាដើម្បីទាមទារឯករាជ្យពីបារាំង។ យួនគិតថា បើយួនអាចបង្កើតចរន្តនយោបាយមួយដ៏មានអនុភាពក្រោមការគ្រប់គ្រងរបស់យួននៅកម្ពុជានិងលាវ  យួននឹងឈានទៅគ្រប់គ្រងប្រទេសទាំងពីរនេះអោយនៅជាចំណុះយួន។ ម៉្យាងយួនដឹងថា នៅដំណាក់ទៅមុខ យួនត្រូវការទឹកដីនិងធនធាននៃប្រទេសទាំងពីរដើម្បីពង្រឹងប្រទេសយួននិងប្រជាជនយួន ដូច្នេះមេដឹកនាំយួនដឹងថា តើត្រូវធ្វើអ្វី ហើយយួនមានធនធានមនុស្សនិងបង្អែកដើម្បីសម្រេចផែនការណ៍ទាំងនេះ ។ បន្ទាប់ពីបាន**បង្កើតបក្សកុំម្មុយនីស្តឥណ្ឌូចិន**នៅឆ្នាំ១៩៣០ យួនបានបើកយុទ្ធនាការយោធានិងនយោបាយនៅកម្ពុជា លាវ និងនៅថៃឡង់ ដោយបានបញ្ជូនភ្នាក់ងារយួនមកបង្កប់ក្នុងប្រទេសទាំងនោះដើម្បីរៀបចំបណ្ដាញក្រុមការងារនិងចរន្តនយោបាយដែលយួនចង់បាន។  ចាប់ពីឆ្នាំ១៩៤០-១៩៤១ មកយើងសង្កេតឃើញមានការបង្កើតចលនាផ្សេងៗដឹកនាំដោយយួនវៀតមិញនៅកម្ពុជា លាវ និងថៃឡង់។ ពួកយួនទាំងនោះសុទ្ធតែជាភ្នាក់ងារឬសមាជិកនៃអង្គការកុំម្មុយនីស្តឥណ្ឌូចិនឬអង្គការវៀតមិញដែលយួនបញ្ជូនមកបង្កប់អោយខ្លួននៅកម្ពុជា លាវ និងនៅថៃឡង់ ដើម្បីធ្វើសកម្មភាពយោធានិងនយោបាយយ៉ាងសកម្មជាមួយក្រុមជាតិផ្សេងៗ ដូចជានៅស្រុកខ្មែរ ពួកវៀតមិញបានចូលរួមបង្កើតចលនាឥស្សរៈដឹកនាំដោយអាចារមាន និងអាចារសុខមុនពេលដែល ដាប-ឈួន និងទ្រង់ ច័ន្ទ-រង្សី បានចូលខ្លួនបំរើចលនានោះនៅឆ្នាំ១៩៤៦។

ការពិតចលនាឥស្សរៈជាចលនាត្រូវបានបង្កើតឡើងនៅឆ្នាំ**១៩៤០** ដោយជនជាតិថៃម្នាក់ឈ្មោះ ផុក-ឃុន សហការជាមួយពួកវៀតមិញឬខ្មែរឆ្វេងនិយមដើម្បីទាមទារឯករាជ្យពីបារាំងដូចគ្នានឹងចរន្ត**បក្សកុំម្មុយនីស្តឥណ្ឌូចិន**របស់យួនដែរ ។ ពេលជាមួយគ្នាដែរ  លោក សឺង-ងុកថាញ់ បានបង្កើតចលនាទាមទារឯករាជ្យពីបារាំង១ទៀត ជាមួយព្រះសង្ឃស្នេហាជាតិជាច្រើនមាន ៖ សម្ដេចសង្ឃ **ជួន-ណាត**, មហា-មុនី **អ៊ុម-ស៊ូ**, ព្រះមហាព្រហ្មមុនី-**អ៊ូ**, សម្ដេចសង្ឃ **ហួត-តាត** , អាចារ្យ **ខៀវ-ជុំ**, លោកគ្រូ **ប៉ាង-ខាត់**, អាចារ្យ **ហែម-ចៀវ**, លោក **ជុំ-មួង**, លោក **ស៊ឹម-វ៉ា**, លោក **ប៊ុន ចន្ទ-ម៉ុល**, លោក **ប៉ាច-ឈឺង**, លោក **ប៊ូវ-ហ៊ង**, លោក **ង៉ោ-ហុង** ។ល។ លោក សឺង-ងុកថាញ់ និងក្រុមលោកក៏បានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងបារាំងជាមួយពួកឥស្សរៈនិងវៀតមិញនៅភ្នំពេញនៅឆ្នាំ ១៩៤២។

នៅឆ្នាំ១៩**៤៦** ពេលដែលពួក**បក្សកុំម្មុយនីស្ត**ថៃចុះខ្សោយ ហើយបានបាត់បង់ខេត្តសៀមរាបនិងបាត់តំបងមកខ្មែរ ពួកថៃក៏បានមកទាក់ទងនិងជួយដល់ ដាប-ឈួន និងនរោត្តម ចន្ទ័-រង្សី ។ នៅឆ្នាំ **១៩៤៨** ចលនាឥស្សរៈបានបង្កើត **គណកម្មធិការរំដោះជាតិខ្មែរ** ដឹកនាំដោយ ដាប-ឈួន ដែលមានទ្រង់ ច័ន្ទ-រង្សី ជាមេបញ្ជាការ ។ ក្នុងចំណោមថ្នាក់ដឹកនាំឥស្សរៈទាំង១១ នាក់ មាន៥នាក់ជាពួកវៀតមិញ។ ដោយមានការមិនពេញចិត្តនឹងលោក ដាប-ឈួន និងទ្រង់ ច័ន្ទ-រង្សី ព្រោះអ្នកទាំងពីរនេះព្យាយាមធ្វើអោយចលនាយួនមួយនេះក្លាយជារបស់ខ្មែរ  (Khmerisation a Yuon´s movement) ពួកនេះក៏បានចាកចេញទៅបង្កើតក្រុមមួយផ្សេងទៀតឈ្មោះ **រណសិរ្សបង្រួបបង្រួមឥស្សរៈ  នៅឆ្នាំ**


រក្សាសិទ្ធិគ្រប់យ៉ាង

**១៩៥០** ដឹកនាំដោយ សឹង-ង៉ុកមិញឬអាចារមាន និង ទូ-សាមុតឬអាចារសុខ ដើម្បីវាយបំបែក**គណកម្មធិការរំដោះជាតិខ្មែរ** ដឹកនាំដោយ ដាប-ឈួន និងទ្រង់ ច័ន្ទ-រង្សី ។ ក្នុងចំណោមខ្មែរឥស្សរៈវៀតមិញ មានតែ **សៀវ-ហេង និងក្មួយលោកគឺឡុង-ប៊ុនរត់ឬនួន-ជាទេដែលនៅគាំទ្រ** **គណកម្មធិការរំដោះជាតិខ្មែរ** ។ ដោយមានជំនួយយោធានិងនយោបាយផ្ទាល់ពីយួន ចលនាបង្រួបបង្រួមឥស្សរៈដឹកនាំដោយសឹង-ង៉ុកមិញបានវាយបំបែកចលនាខ្មែរឥស្សរៈដឹកនាំដោយលោក ដាប-ឈួន និងទ្រង់ ច័ន្ទ-រង្សី រហូតរលត់រលាយអស់ ។ ពួក **រណសិរ្សបង្រួបបង្រួមឥស្សរៈ** បានបង្កើតរដ្ឋាភិបាលមួយឈ្មោះថា "រដ្ឋាភិបាលខ្មែរតស៊ូ" **'Khmer Resistance Government'**

នៅចុងឆ្នាំ១៩៤៨ ចលនាតស៊ូក្នុងស្រុកខ្មែរចែកចេញជា ៤ តំបន់៖ ក្រុមដឹកនាំដោយលោក ដាប-ឈួន គ្រប់គ្រងនៅតំបន់ពាយ័ព្យនិងបីតំបន់ទៀត( តំបន់ស្វ័យយ័ត្ន )គ្រប់គ្រងដោយពួកវៀតមិញនិងខ្មែរវៀតមិញឬខ្មែរឥស្សរៈយួន។ **គណកម្មធិការរំដោះជាតិខ្មែរ** ដឹកនាំដោយ ដាប-ឈួនបានផ្តាច់ខ្លួនបន្តិចៗពីក្រុមយួនឬក្រុមកំម្មុសនីស្តហើយបន្ទាប់មកត្រូវរលត់រលាយអស់តែម្តង។ តាមឯកសារយួននៅឆ្នាំ១៩៥០ **រណសិរ្សបង្រួបបង្រួមឥស្សរៈ** មានសមាជិករហូត ១៥០០០០ ដែលផ្សំដោយកងទ័ពជាតិយួននិងខ្មែរដែលយួនដើរកេណ្ឌតាមបំបន់នានាអោយបំរើក្នុងជួរ**រណសិរ្សបង្រួបបង្រួមឥស្សរៈ** ពួកនេះបានធ្វើប្រតិបត្តិការយោធានិងមនោគមន៍វិជ្ជាកុម្មុនីស្តពាសពេញផ្ទៃប្រទេសខ្មែរ។ ចលនាឥស្សរៈឬចលនា**រណសិរ្សបង្រួបបង្រួមឥស្សរៈ**( ក្រៅពីក្រុមលោកដាបឈួននិងទ្រងច័ន្ទរង្សី )គឺ**ជា**ចលនាឆ្វេងនិយមបង្កើតនិងដឹកនាំដោយយួនឬ**បក្សកុំម្មុយនីស្តឥណ្ឌូចិន** ពួកនេះប្រតិបត្តិការជាមួយយួនដូចជាក្រុមតែមួយរហូតដល់ឆ្នាំ១៩៥១ ទើបយួនសម្រេចចិត្តបំបែកអោយមានក្រុមតាមប្រទេសនិមួយៗតែយួននៅតែរក្សាការគ្រប់គ្រងទាំងស្រុងលើក្រុមទាំងនេះ។

នៅឆ្នាំ១៩៥៤ បន្ទាប់ពីសន្និសិទក្រុងហ្សឺណែវ "បក្សប្រជាជនបដិវត្តន៍កម្ពុជា" បានបំបែកខ្លួនចេញជា**បីក្រុម** ៖

ក្រុមទី១ ដឹកនាំដោយ **សឹងង៉ុកមិញ, កែវមុន្នី, មីផូ, រត្តសាមឿន, ប៉ែនសុវណ្ណ** ( មានយុវជន២៥០០នាក់ បានត្រូវយួននាំទៅស្រុកយួន ក្នុងទិសដៅទុកប្រើប្រាស់នៅតំណាក់កាលក្រោយតាមគម្រោងដែលយួនបានគិតទុកនិងម៉្យាងទៀតវាជាល្បែងផ្តិនភ្នែកដើម្បីបោកប្រាស់អន្តរជាតិដោយសម្របតាមសន្និសិទក្រុងហ្សឺណែវ )

ក្រុមទី២ ដឹកនាំដោយ សឹង-ង៉ុកមិញ **នង-សួន, កែវ-មាន, ប៉ែន-យុទ្ធ** បានបង្កើតគណបក្សនយោបាយមួយឈ្មោះថា **បក្សប្រជាជន** ដើម្បីចូលរួមបោះឆ្នោតសភានៅឆ្នាំ ១៩៥៥ និង១៩៥៨ ។

ក្រុមទី៣ ដឹកនាំដោយ **ទូ-សាមុត សៀវ-ហេង, នួន-ជា, សោ-ភឹម, និង ណៃ-សារ៉ន** ធ្វើសកម្មភាពយោធាលួចលាក់ដោយពួកនេះនៅមានមូលដ្ឋានតស៊ូទាំង៤តំបន់ ។ ទូ-សាមុត ជាមេរបស់ ប៉ុល-ពត ធ្វើសកម្មភាពជាមួយគ្នានៅ ភ្នំពេញ។

ដោយប្រវត្តិសាស្ត្រពិតត្រូវឃាតករលោក់បាំង ក្រឡៃបំភាន់និងលាងសំអាតផង ថ្មីៗនេះខ្មែរមួយចំនួនមានការភ្ញាក់ពេលដែលបានដឹងថា គណបក្សប្រជាជនកម្ពុជា មានការវិវត្តន៍ពី គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ឬគណបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាគណបក្សបង្កើតឡើងដោយយួន ឡេ-ដុកថូ ជាមួយពួកខ្មែរវៀតមិញ(វៀតមិញនិងខ្មែរឥស្សរៈយួន)នៅឆ្នាំ ១៩៥១ ។ គណបក្សនេះបានក្លាយជាគណបក្សនយោបាយដ៏មានឥទ្ធិពលតែមួយគត់នៅកម្ពុជានិងបានគ្រប់គ្រងនយោបាយសេដ្ឋកិច្ចនិងយោធានៅកម្ពុជាទាំងស្រុងចាប់ពី ឆ្នាំ១៩៧៩ មករហូតបច្ចុប្បន្ន។ ចាប់ពីពេលបដិសន្ធិនៅឆ្នាំ ១៩៥១ រហូតដល់ឆ្នាំ១៩៦០ គណបក្សប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានដឹកនាំដោយ សឺង-ង៉ុកមិញ ហៅ អាចារ្យមាន ឬឈ្មោះជាយួនហៅថា ផាម-វ៉ាន់ហៅ *Pham Van Hua* ដែលជាមេដឹកនាំខ្មែរឥស្សរៈយួនឬចលនាបង្រួបបង្រួមឥស្សរៈដែលជាចលនាបំបែកខ្លួនចេញពីចលនាខ្មែរឥស្សរៈដឹកនាំដោយលោក ដាប-ឈួន និង ទ្រង់ច័ន្ទ-រង្សី។ ការពិតការបង្កើតគណបក្សប្រជាជនបដិវត្តន៍កម្ពុជាឬគណបក្សប្រជាជនបដិវត្តន៍ខ្មែរនៅឆ្នាំ១៩៥១ ជាតំណាក់ការទីបីនៃយុទ្ធសាស្ត្រនយោបាយអង្គការសហព័ន្ធឥណ្ឌូចិន។ សមាសភាពមនុស្សដែលយួនយកមកបង្កើតនិងដឹកនាំគណបក្សប្រជាជនបដិវត្តន៍កម្ពុជានៅឆ្នាំ១៩៥១ និងបន្ទាប់មកទៀតនៅឆ្នាំ១៩៧៩ សុទ្ធសឹងតែជាអតីតខ្មែរឥស្សរៈយួនឬខ្មែរវៀតមិញនិងយួនវៀតមិញ។ ក្នុងសៀវភៅរបស់លោកអង់ជ្រេតុង «ស៊ីហានុចុងបញ្ចប់នៃការបោកបញ្ឆោត » លោកបានសរសេរថា ពួកវៀតមិញដែលគេបញ្ជូនពីស្រុកយួនមកធ្វើជាខ្មែរវៀតមិញឬមេដឹកនាំខ្មែរវៀតមិញ សុទ្ធសឹងជាកងទ័ពជាតិយួនដឹកនាំដោយង្វៀនយ៉ឺនយ៉ាប់។

នៅថ្ងៃទី២៨-៣០ កញ្ញា **១៩៦០** នូវពេលដែលតំណែង គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ត្រូវបានផ្ទេរមកអោយ អាចារ្យ-សុខ ឬទូ-សាមុត ឈ្មោះ បក្សប្រជាជនបដិវត្តន៍កម្ពុជា ត្រូវបានប្តូរមកជា បក្សពលករកម្ពុជា វិញដើម្បីអោយស្របជាមួយបក្សពលករយួន។ គួរកត់សំគាល់ថា ទូ-សាមុត ត្រូវបាត់ខ្លួននៅ ខែ**កក្កា១៩៦២** ដូច្នេះ ប៉ុល-ពត ត្រូវឡើងជា លេខាស្តីទីជំនួស ទូ-សាមុត រហូតដល់ថ្ងៃទី២០-២១ **កុម្ភៈ១៩៦៣** ទើបប៉ុល-ពត ក្លាយជាលេខាពេញទី បន្ទាប់ពីមានអង្គប្រជុំនៅការិយាលយ័ននយោបាយរបស់ នួនជា, អៀងសារី, សោភឹម, វនវេន ។

នៅខែមិថុនា **១៩៦៥**, ប៉ុល-ពត និង កែវមាស បានដឹកនាំប្រតិភូមួយក្រុមចាកចេញពីជុំរុំ១០០ ធ្វើដំណើរតាមផ្លូវលំហូជីមីង ទៅហាណូយ និង ប៉េកាំង ដើម្បីជួបជាមួយ ឡេ-យុន, ម៉ៅ-សេទុង, ឡូ-ចៅជី និង តេង-សាវពីង ។ (តើដំណើរទស្សនកិច្ច របស់ប៉ុល-ពត នៅឆ្នាំ ១៩៦៥ ទៅស្រុកចិន និងយួននៅពេលនោះ ទំនងជាការទៅសុំភ្លើងបៃតងពីចិននិងយួន ដើម្បីអោយចិននិងយួនទទួកស្គាល់មុខតំណែងខ្លួនជាមេបក្សកុំម្មុនីស្តកម្ពុជាជំនួសទូសាមុតឬក៏ទៅទទួលបញ្ជាថ្មីពីចិននិងយួន ?)

បន្ទាប់ពីត្រលប់មកពីស្រុកចិននិងស្រុកយួន វិញ ប៉ុល-ពត បានបើកមហាសន្និបាត ហើយបានប្តូរឈ្មោះបក្សពលករកម្ពុជា មក ជា"**បក្សកុំម្មុយនីស្តកម្ពុជា**" គឺជាថ្ងៃដែល ប៉ុល-ពត ចូលជាសមាជិកមជ្ឈឹមបក្សកុំម្មុយនីស្តកម្ពុជា ។ បន្ទាប់មកប៉ុល-ពត បានចាក ចេញពីជុំរុំ ១០០ នៅក្រូចឆ្មា មកនៅរតនគីរី វិញ ព្រោះអាមេរិកទម្លាក់គ្រាប់បែកខ្លាំងពេក (ជុំរុំ ១០២, ១០៤ កាន់ដោយ សុន សេន, កែវ មាស, អៀងសារី, សុខ ខុល, សោភិម, ណៃ សារ៉ន)

នៅឆ្នាំ១៩៦៧, បន្ទាប់ពីមានព្រឹត្តិការណ៍នៅ សំឡូត ហើយស៊ីហនុ បានចោទប្រកាន់ទៅលើតំណាងរាស្ត្រ **ហ៊ូនឹម ហ៊ូយន់ ខៀវ សំផន** ពួកគេបានរត់ទៅពួននៅភ្នំក្រវាញ ។ យោងតាមសៀវភៅរបស់អ្នកស្រី **ម៉ារីអាលិចសង់ម៉ាកតាំង « ជម្ងឺកម្ពុជា »** ក្នុងចំណោមពួកនិសិត្សក្រហមទាំងអស់ដែលបានមកសិក្សានៅបារាំង មានតែ លោក ហ៊ូនឹម ហ៊ូយន់ ទេ ដែលបដិសេធលទ្ធិកុំម្មុយនីស្តបែបស៊ីហនុនិយម មានន័យថា និន្នាការនយោបាយកុំម្មុយនីស្តព្យាក្រិត តែរិតសម្ពន្ធ័ស្អិតរមួតជាមួយចិននិងយួន ធ្វើសកម្មភាពក្រោមការគ្រប់គ្រងរបស់យួននិងដោយជំនួយពីចិន ។ ពួកលោកជាមនុស្សដែលស៊ីហនុស្អប់បំផុត ។ តាមការពិតថ្វីបើ លោក ហ៊ូនឹម ហ៊ូយន់ ស្រលាញ់លិទ្ធិកុំម្មុយនីស្តមែនតែលោកចង់បានការដឹកនាំមួយរបៀបប្រទេសបារាំង មានន័យថា កុំម្មុយនីស្តបែបសភានិយម ដែលឯករាជនិងធ្វើការតស៊ូមតិនិងនយោបាយក្នុងសភាដូចប្រទេសបារាំង ។ល។ បុស្បាអង្គរ

ប្រភពឯកសារ៖

http://amekhmer.free.fr/khcrucial-event/1crucial-eventpage.htm

http://devaraja.free.fr/Khmer-books/1khmerbook-page.htm

http://amekhmer.free.fr/khcrucial-event/sihanouk-crime/1cambogeno1.html

http://amekhmer.free.fr/khcrucial-event/1sothpolin/1bestof-sothpolin.htm

http://devaraja.free.fr/1Opinion/2Opinion-home.htm

http://amekhmer.free.fr/khcrucial-event/0mtes-tum-files/0mtes-tum.htm

http://amekhmer.free.fr/khcrucial-event/sihanouk-crime/sihanouk-crimekh.ram